ខ្ញុំគ្រាន់តែជាជាងគំនូរម្នាក់ ចំណែកគេគឺជាកូនអ្នកមាន។ ពាក្យថា«អ្នកមាន»នៅទីនេះ គឺមិនសមណាខ្ញុំមាននិស្ស័យបានស្គាល់ ហើយបេះដូងហ៊ានទៅរំញោចនឹកគិតដល់គេនោះទេ។

រឿងហេតុគឺកើតឡើងដោយចៃដន្យបំផុត។

ខ្ញុំជាអ្នកធ្វើការនៅក្នុងសណ្ឋាគារធំមួយ ជាកម្មសិទ្ធិរបស់គ្រួសារគេ។ តួនាទីខ្ញុំជាអ្នកថែទាំរូបគំនូរលាបពណ៌ថ្មី ជួសជុល ដុះខាត់ ដែលខ្ញុំខ្លួនឯងក៏ជាជាងគំនូរម្នាក់ មិនទាន់ល្បីឈ្មោះ។

ការលាបពណ៌វាមិនងាយស្រួលពិតមែន ប៉ុន្តែកាលដែលចង់លុបពណ៌ផ្កាឈូកចេញពីបេះដូងរបស់យើងរឹតតែមិនងាយស្រួល ដូចការដាក់ទឹកថ្នាំពណ៌ខ្មៅមកគ្របពីលើផ្ទាំងគំនូរនីមួយៗនោះទេ។

រឿងហេតុរបស់ពួកយើងដែលបានកើតមានឡើងមក ខ្ញុំមិនដឹងថាត្រូវអរគុណដល់ព្រះព្រហ្មលិខិត ដែលបានប្រទាននូវឱកាសឲ្យខ្ញុំបានឃើញគេ បានស្គាល់ពីអារម្មណ៍កក់ក្ដៅនិងការឈឺចាប់នៅក្នុងសេចក្ដីស្នេហាជាមួយគេ ដែលអ្នកសិល្បៈដូចខ្ញុំគួរតែមានបទពិសោធ ប៉ុន្តែពេលខ្លះខ្ញុំក៏យល់ថា បើសិនអ៊ីចឹងដដែលទេ តើខ្ញុំជួបគេដើម្បីអីទៅ?

ជារៀងរាល់ថ្ងៃ ខ្ញុំតែងតែឱបជាប់នូវទស្សនាវដ្ដីមួយដែលមានរូបរាងរបស់គេលើគ្របមុខ។ គេជាកូនស្រីពៅនៃត្រកូលអភិជន អ្នកមានកប់ពពកល្បីឈ្មោះនៅក្រុងភ្នំពេញ។

គេមិនសូវមករស់នៅប្រទេសខ្មែរទេ ព្រោះជាប់រៀននៅស្រុកក្រៅតាំងពីតូចៗ ប៉ុន្តែអ្នកក្នុងស្រុកយើងដឹងថា គេជាអ្នកពូកែខាងវិចិត្រកម្មកំព្យូទ័រម្នាក់ដែលមានស្នាដៃឌីហ្សាញនៅបណ្ដាកម្មវិធី Fashion Of The Week ជាច្រើនប្រទេសមកហើយ។

ខោអាវគេគូរបានល្អនិងមានកេរ្ដិ៍ឈ្មោះល្បីលើឆាកអន្ដរជាតិ ប៉ុន្តែខ្ញុំមិនដឹងថាគេចេះគូរគំនូរផាត់ពណ៌ដែរឬក៏អត់ទេ។

នៅក្នុងបន្ទប់ជួលរបស់ខ្ញុំមានកន្លែងសម្ងាត់ដែលខ្ញុំលបលួចលាក់រូបគំនូរអាថ៌កំបាំងជាច្រើន។ គ្មានគំនូរអ្វីក្រៅពីការលួចគូររូបនានាអំពីគេនោះទេ។

រូបភាពរបស់គេលើទស្សនាវដ្ដីជាកូនស្រីមហាសេដ្ឋីស្រុកខ្មែរ ត្រូវបានខ្ញុំយកមកផាត់តុបតែង លុបចោលនូវសម្លៀកបំពាក់អភិជន ជំនួសមកវិញនូវក្រមា ហូល សារ៉ុង ដែលខ្ញុំគិតថាគេរឹតតែស្អាតឡើងៗ បរិសុទ្ធឡើងៗជាងអ្វីគ្រប់យ៉ាងលើលោកនេះ។

គូរចប់កាលណា ខ្ញុំមូរទុកក្នុងថតក្រោមគ្រែ សូម្បីសុធីជាមិត្តស្នាក់ជាមួយគ្នាក៏មិនអាចដឹងរឿងនេះបាន។

«ថ្ងៃនេះអ្នកនាងភស្សនាបង្ហាញមុខគួរដណ្ដឹងហើយ!»

ខ្ញុំសឹងតែរបូតជក់ពីដៃ ពេលដែលកំពុងតែផាត់ពណ៌ប្រេងថើៗលើផ្ទាំងគំនូរចាស់មួយ ដើម្បីបង្កើនសោភ័ណភាពវាឡើងវិញក្រោយត្រូវបានកណ្ដៀរសត្វខាំ។

ឈ្មោះរបស់នាងកម្រមានណាស់ គឺមានតែម្នាក់ប៉ុននោះ។ ទោះបីនាងទៅរៀននៅស្រុកគេយូរមកហើយ ក៏មិនដែលដាក់ឈ្មោះបរទេសផ្សេងអ្វីដែរ នាងនៅតែឱ្យគេហៅថាភស្សនា ទាំងផ្លូវការនិងមិនផ្លូវការ។

Designerខ្មែរនាម ទេពីភស្សនា គឺជានារីម្នាក់ដែលគ្រប់គ្នាស្គាល់ច្បាស់ ព្រោះគេជាកូនអភិជនម្នាក់ និងមានឈ្មោះបោះសំឡេងខ្លាំងព្រោះរូបសម្រស់និងស្នាដៃ។

ការតាមដានជីវិតឯកជនរបស់នាងសឹងក្លាយជារឿងធម្មតាសម្រាប់បុគ្គលិកគ្រប់គ្នានៅទីនេះទៅហើយ។

«ម៉េចក៏របូតជក់បាត់ទៅហើយវីរ៉ា? តិចកាត់ប្រាក់ខែ!»

នេះគឺសម្ដីរបស់មេក្រុមខ្ញុំឈ្មោះប៊ុន ចាន់ថុល គាត់តែងតែនិយាយលេងទៅតាមចរិតរួសរាយនិងមាននិងមានរូបរាងធាត់ទ្រលុកចិត្តល្អ គួរឲ្យស្រឡាញ់ ប៉ុន្តែលើកនេះខ្ញុំគ្មានអារម្មណ៍សើចលេងនឹងគាត់ដូចរាល់ដងទៀតនោះទេ។ បេះដូងខ្ញុំកំពុងរបួស! វាដូចជាត្រូវគេចាក់ឈឺបៗជាមួយនឹងអ្វីមុតៗអាចជាម្ជុលតូចៗ មើលមិនឃើញ តែឈឺណាស់។

ខ្ញុំនិងគេមិនដែលសូម្បីតែឃើញគ្នានៅខាងក្រៅផង កុំថាឡើយដល់ទៅនិយាយរកឬជាប់សន្យាអ្វីរឿងបេះដូង ម៉េចក៏ដំណឹងភ្ជាប់ពាក្យរបស់គេបង្កបានឱ្យខ្ញុំនូវអារម្មណ៍ឈឺចាប់ខ្លាំងកម្រិតនេះបាន?

ខ្ញុំក៏មិនដែលរំពឹងទុកថា ថ្ងៃណាមួយនឹងបានគេមកញញឹមដាក់ ឬសូម្បីតែគេដៀងភ្នែកមកមើលខ្ញុំចុះហេតុអីក៏នៅតែឈឺ?

«ប៉ុន្តែឮសូរមកថា អ្នកនាងពៅខឹងចំពោះការភ្ជាប់ពាក្យដែលមិនឲ្យគាត់ដឹងមុននេះ! គាត់មិនព្រមមកស្រុកខ្មែរទេ!»

សំឡេងមីងអនាម័យខ្សឹបដាក់បងថុលដូចរាល់ដង។ ពីរនាក់គាត់ត្រូវគ្នាណាស់ព្រោះមានស្រុកកំណើតជាមួយគ្នា។ តាមធម្មតាខ្ញុំមិនចង់ដឹងឮរឿងពួកគេជជែកគ្នាទេ ពួកគាត់មានរឿងមិនចេះខ្វះមកជជែកគ្នារាល់តែថ្ងៃ ប៉ុន្តែប្រធានបទទាក់ទងនឹងនាង ខ្ញុំមិនចង់រំលងឡើយ។

ទីបំផុតខ្ញុំបានដំណឹងច្បាស់មកថា គេត្រូវប៉ាម៉ាក់បង្ខំឲ្យត្រឡប់មកភ្នំពេញវិញជាបន្ទាន់ ដើម្បីត្រៀមភ្ជាប់ពាក្យជាមួយកូនប្រុសមន្ត្រីធំម្នាក់។ ស្ថានភាពគ្រួសារម្នាក់នោះអាចថា ធំលើសពីគ្រួសាររបស់នាងទៅទៀត។ ខ្ញុំយល់ពីអារម្មណ៍ជាយុវវ័យដែលមានអ្វីគ្រប់យ៉ាង ប៉ុន្តែគ្មានសេរីភាពនៅក្នុងការជ្រើសរើសមនុស្សដែលខ្លួនស្រឡាញ់។

នាងមិនសប្បាយចិត្តជារឿងធម្មតា តែបើគិតតាមភាពជាក់ស្តែង នាងសមណាស់នឹងបុរសម្នាក់នោះ។ គេមកពីវង្សត្រកូលល្អហើយគ្រួសារទាំងពីរចុះសម្រុងនឹងគ្នា ពួកគេចូលស្តីដណ្តឹងនាងដល់ពុកម្តាយទៅហើយ មានអីមិនល្អទៅ?

យប់នោះ ពេញមួយយប់បានសុធីមិននៅ ខ្ញុំឆ្លៀតគូរបានគំនូរមួយផ្ទាំងថ្មីរបស់នាងក្នុងឈុតកូនក្រមុំខ្មែរ ជានាងនាគពាក់ស្បៃយ៉ាងស្រស់ស្អាត។

នៅគ្រប់ដង្ហើមពេលដែលខ្ញុំវាសជក់ខ្ញុំតែងតែឆ្លៀតខ្សឹប ជូនពរគេឲ្យគេបានទទួលនូវជោគជ័យនៅក្នុងជីវិតអាពាហ៍ពិពាហ៍ រស់នៅប្រកបដោយសុភមង្គល។

ចាស់ៗចំណាំតែនិយាយថា បើសិនជាកាលពីជាតិមុនយើងធ្លាប់មាននិស្ស័យបុណ្យជាមួយគ្នា ឬក៏ធ្លាប់ទៅវត្តជាមួយគ្នា ធ្លាប់ធ្វើអំពើសប្បុរសណាមួយជាមួយគ្នា ប្រាកដជាជាតិនេះមាននិស្ស័យ បានជួបគ្នាតិចតួចដែរ។ សង្ឃឹមថាការឈឺចាប់មួយនេះ ឬហៅថាការកក់ក្តៅតិចតួចនេះនិងអនុស្សាវរីយ៍ទាំងប៉ុន្មានដែលមានតែម្ខាងនេះ ខ្ញុំនឹងបញ្ចប់បានត្រឹមថ្ងៃនេះទៅចុះ គឺថ្ងៃដែលឃើញមុខគូជីវិតគេហើយ ក៏អស់ចិត្តហើយ។

គំនូរនេះ ខ្ញុំប៉ងថានឹងផ្ញើតាមបងចាន់ថុលនៅថ្ងៃរៀបការរបស់គេ ទៅជូនគេ។

ខ្ញុំសរសេរឈ្មោះខ្លួនឯងតូចមួយនៅជាយខាងក្រោមថា វីរ៉ា។

ឈ្មោះរបស់ខ្ញុំក្នុងនាមជាវិចិត្រករ គឺជាអ្វីដែលខ្ញុំស្រឡាញ់បំផុតមួយក្នុងជាតិនេះ ប៉ុន្តែក៏មិនដឹងថាអនាគតរបស់ខ្ញុំរំពឹងលើអ្វីនោះនៅឡើយព្រោះថាបណ្តាស្នាដៃគំនូររបស់ខ្ញុំ មិនដែលបានលេចធ្លោនៅក្នុងប្រទេសឬក្រៅប្រទេសនៅឡើយ។ ក្តីស្រមៃទទួលបានពានរង្វាន់នៅក្រៅប្រទេស និងក្តីស្រមៃថាបានមនុស្សស្រីម្នាក់នេះមកនៅក្បែរ សុទ្ធតែជាអ្វីមួយ«គ្មានរំពឹង»ឡើយសម្រាប់ខ្ញុំ។

ទីបំផុតខ្ញុំបានត្រឹមជាអ្នកមើលថែរូបគំនូរនៅក្នុងសណ្ឋាគាររបស់ប៉ាគេ ហើយសូម្បីតែមុខប៉ាគេនិងគេ ក៏ខ្ញុំមិនដែលបានជួបផ្ទាល់ម្តងផង។

ទោះបីជាមានកម្មវិធីធំៗដែលពួកគេបង្ហាញវត្ថុមាន ក៏កម្របំផុតនឹងឱ្យបុគ្គលិកឋានៈប៉ុនខ្ញុំបានទៅចូលរួម។

«ហេ វីរ៉ា! វីរ៉ា? វីរ៉ាឯងស្អែកនេះត្រូវទៅចាត់ចែងរៀបចំនៅផ្ទះមេជំនួសបង!»

ពាក្យថាមេ គឺសំដៅប៉ារបស់គេ។ ខ្ញុំដឹងថា គេបានមកដល់ភ្នំពេញហើយ ព្រោះពិធីភ្ជាប់ពាក្យជិតដល់កាលកំណត់។ បេះដូងខ្ញុំលោតក្តុកក្តាក់ អមជាមួយសំណួរចេញពីមាត់ខ្ញុំត្រឡប់ទៅបងចាន់ថុល៖

«មានរឿងអីបង?!»

«អ្ហើយ ម្តាយក្មេកខ្ញុំដូចជាគាត់ធ្វើបាបខ្ញុំហ្មង! គាត់ឈឺចំថ្ងៃដែលខ្ញុំត្រូវតែធ្វើការនៅផ្ទះមេ! គាត់ចង់ឲ្យខ្ញុំបាត់បង់ការងារមើលទៅ! ឥឡូវប្រពន្ធខ្ញុំខលមកឱ្យប្រញាប់ជូនម៉ែគេដាក់ឡានទៅស្រុក!»

«គាត់ឈឺម៉េចក៏មិនទៅពេទ្យ ទៅស្រុកធ្វើអីបង?!»

«គាត់ជឿលើពេទ្យនៅស្រុកគាត់ជាង! អឺ...ត្រៀមទៅ ស្អែកឯងជាមួយសុធីដឹកនាំកម្មករដេគ័រទៅផ្ទះមេ!»

«ប៉ុន្តែបង...មានអីខ្លះធ្វើ? ខ្ញុំអត់ដែលទៅផ្ទះគាត់ ខ្ញុំមិនដឹងកន្លុកកន្លៀតទេបង!»

«កុំស្មុគពេក សុធីធ្លាប់ទៅច្រើនដងជាមួយបងដែរហើយ!»

សុធីជាអ្នកស្នាក់បន្ទប់ជាមួយខ្ញុំ ជាមិត្តខ្ញុំបានចេញមុខធានានិងណែនាំខ្ញុំឱ្យមកចូលធ្វើការនៅទីនេះ គេក៏ជាជំនួយការរបស់បងថុលដែរ។ ទោះបីសុធីមិនចេះរៀបចំផ្ទាំងគំនូរ មិនចេះមើលវត្ថុសិល្បៈត្រឹមត្រូវ ថែមមិនចេះជួសជុល ប៉ុន្តែគេថ្នឹកខាងពិធីការ ពូកែខាងដឹងកន្លុកកន្លៀតផ្ទះមេ ព្រោះឲ្យតែមានកម្មវិធីអ្វី មានបងថុលនិងធីទៅពិនិត្យរៀបចំតុបតែងជានិច្ច។

«មិនបាច់រៀបចំពេកក៏បាន គ្រាន់តែថាពេលដែលពិធីចាប់ផ្តើមយើងមិនមានឱកាសបាននៅតទេ គ្មានឡើយវាសនាសូម្បីត្រឹមតែបានឃើញកូនស្រីអភិជនទាំងអស់នោះ គឺត្រូវបានគេដេញចេញមកវិញដូចតែរាល់ដងហ្នឹងអារ៉ា!»

សុធីប្រាប់ខ្ញុំពេលខ្ញុំកំពុងខ្ចីតឱនអ៊ុតខោអាវក្នុងបន្ទប់ជួលជាមួយគ្នា។

ទោះយ៉ាងណាមុនពេលពិធីចាប់ផ្តើម ថ្ងៃនេះខ្ញុំនិងសុធីត្រូវបានមេការនៅផ្ទះនោះទូរសព្ទមកប្រាប់ថា ត្រូវត្រៀមសម្លៀកបំពាក់សមរម្យសម្រាប់ពេលយប់ផង ព្រោះថាថៅហ្វាយមិនឲ្យត្រឡប់ទៅវិញទេ នៅជួយបង្ហាញនូវភាពភ្ញាក់ផ្អើលដល់កូនស្រីគាត់នូវរូបគំនូរមួយចំនួនព្រោះថានាងស្រឡាញ់គំនូរ។

«មេឃភ្លៀងហើយ មិនដែលបាននៅក្នុងពិធីជាមួយគេទេ! យីឯងទេដឹង ក្រយៅឯងអាវ៉ា! មកម្តងបាននៅនឹងគេហើយ!»

ខ្ញុំគ្មានអាវធំសមរម្យនោះទេ ដូច្នេះក៏បានខ្ចីអាវពីមិត្តភក្តិម្នាក់ទៀតនៅធ្វើការសណ្ឋាគារជាមួយគ្នា។

ដំណើរទៅកាន់ផ្ទះមហាសេដ្ឋីនេះ យើងមានគ្នា៦នាក់ បានពិនិត្យរៀបចំអ្វីៗគ្រប់យ៉ាងលើជញ្ជាំងមិនឱ្យមានឃ្មើសឬសល់សូម្បីធូលីប៉ុនល្អង។

ពេញមួយព្រឹកហើយ ខ្ញុំនៅតែមិនបានជួបនិងលោកសេដ្ឋីថៅកែខ្ញុំនេះផង កុំថាឡើយដល់កូនស្រីពៅរបស់គាត់។

ទោះយ៉ាងណា ខ្ញុំចាប់អារម្មណ៍ឃើញថា ផ្ទះនេះពោរពេញទៅដោយផ្ទាំងគំនូរនិងរូបភាពសិល្បៈបុរាណសម័យជាច្រើនបញ្ជាក់ថា ម្ចាស់ផ្ទះពិតជាស្រឡាញ់សិល្បៈមិនខុសអ្វីទៅនឹងសណ្ឋាគារដែលពួកគាត់គ្រប់គ្រងនោះទេ ពោលសុខចិត្តជួលជាងគំនូរដូចខ្ញុំមកប្រចាំការដើម្បីគ្រាន់តែកែលម្អវត្ថុសិល្បៈនិងផ្ទាំងគំនូរនានា។

ប៉ឹង.... ខ្វាយ

អ្នកណាម្នាក់ធ្វើបែកវិញម្យ៉ាង។

ដូចស្វ័យប្រវត្តិខ្ញុំងាកទៅរកប្រភពសំឡេង។

នោះគឺនារីរូបស្រស់ស្អាតម្នាក់ ស្អាតណាស់ ស្អាតរហូតដល់ខ្ញុំចង់ភ្លឹក។ គាត់ដើរប៉ះទៅនឹងថូផ្កាមួយ ដោយជាយអាវដ៏វែង។ ដំណើរហើយនិងសម្លៀកបំពាក់បង្ហាញថា គាត់មិនមែនជាអ្នកមកធ្វើការទេគឺជាអ្នកដែលរស់នៅដ៏រំភើយរបៀបអភិជន ព្រោះសូម្បីតែក្នុងផ្ទះក៏គាត់ពាក់ស្បែកជើងកែងចោតដែរ។

ខ្ញុំហៅថា«គាត់»ពីព្រោះមានវ័យលើសខ្ញុំច្រើន អាចថាសែប្លាយហើយតែរូបរាងក៏តារាមិនដូរដែរ។ ពេលគាត់ងាកមក ពិតជាសេដ្ឋីនីឈ្មោះថា ភស្សនា ដែលជាកូនស្រីច្បងរបស់ថៅកែខ្ញុំ យូរៗម្តងធ្លាប់ឃើញគាត់ទៅសណ្ឋាគាររបស់យើងដែរ ប៉ុន្តែមិនមែនជាអ្នកគ្រប់គ្រងនៅទីនោះឡើយ។

នារីនេះមានកេរ្តិ៍ឈ្មោះល្បីព្រោះមានជំនួញជាច្រើនក្នុងដៃទាំងនៅក្នុងនិងក្រៅប្រទេស។

«បែកបាត់ហើយ!»

គាត់និយាយម៉ាត់ៗ ខ្លីៗប៉ុណ្ណឹងក៏កាចណាស់ទៅហើយសម្រាប់ខ្ញុំ។ ខ្ញុំប្រញាប់ងាកមុខចេញ ធ្វើឲ្យគាត់តាមមកហៅពីក្រោយភ្លាមៈ

«ហ៎ អូន! អូន! អ្នកណាហ្នឹង ឈប់សិនមើល៍»

ខ្ញុំត្រូវតែបង្ខំចិត្តងាកទៅជម្រាបសួរគាត់ហើយជម្រាបគាត់វិញថាៈ

«ខ្ញុំជាអ្នកថែរក្សាផ្ទាំងគំនូរមកពីសណ្ឋាគារ បាទ!»

«ជួយរៀបចំរករបស់អីមួយមកតាំងជំនួសកន្លែងនេះវិញ!» គាត់បញ្ជាស្រួយស្រិប។

«បាទទាន!»

ខ្ញុំថយមកពិនិត្យទីនេះវិញ។ នារីអភិជនដើរហួសទៅតែមិនបានប៉ុន្មាន គាត់ក៏ឈប់ហើយបែរមករកខ្ញុំទៀតៈ

«អូ! ឈប់សិនប្អូន! មានគំនូរមួយ ដូចជាប្រលាក់! ថ្ងៃមុនគេមកប្រាប់ខ្ញុំរិះតែនឹងភ្លេច! យើងអាចលាបលម្អថែមឬក៏អត់?!»

«ខ្ញុំសុំមើលសិន!»

ខ្ញុំតបទាំងមិនហ៊ានសម្លឹងគាត់ចំទេ។

«មកតាមខ្ញុំមកអ៊ីចឹង!»

ខ្ញុំត្រូវបាននារីអភិជននាំឡើងមកដល់ជាន់ខាងលើ។ នៅទីនេះពិតជាមានគំនូរមួយផ្ទាំងធំ គ្រាន់តែក្រឡេកក៏ដឹងថា ដឹកយកមកពីប្រទេសឥណ្ឌានិងមានប្រវត្តិកាលយូរលង់ ថែមទាំងប្រើជាតិថ្នាំធុនស្តីកស្អិត ដែលជាមានប្រវត្តិថ្នាំស្មុគស្មាញនៃប្រពៃណីផ្ទា ពិបាកនៅក្នុងការជួសជុលបំផុត។

គ្រាន់តែឃើញនិងប៉ាន់អំពីតម្លៃរបស់វា នៅក្នុងបេះដូងខ្ញុំគឺញាប់ញ័រសឹងតែមិនហ៊ានធ្វើការប៉ះពាល់ច្រើនផងកុំថាឡើយដល់ហ៊ានជួសជុល។ ជើងខ្ញុំឈានឡើងលើជណ្ដើរខ្លី សម្លឹងវត្ថុកម្រទាំងនេះទាំងចិត្តស្ងប់ស្ងៀង។ ហត្ថវិចិត្រកម្មនេះ សមណាតែរក្សាទ្រង់ទ្រាយនិងសភាពដើមទាំងស្រុងតាម

ដែលដែលអាចធ្វើទៅបាន ល្អជាង។ សូម្បីតែសម្អាតបន្តិចណា ក៏សឹងស្ដាយចំណុចល្អិតៗជាពន់ពេកណាស់។

ដូច្នេះខ្ញុំបាននិយាយប្រាប់គាត់ថា៖

«ជម្រាបប្រសាសន៍លោកជំទាវ គំនូរនេះគួរតែមិនប៉ះពាល់ល្អជាង!»

«ប្អូនមិនចេះធ្វើឬក៏យ៉ាងម៉េច? ចុះស្គាល់ជាងផ្សេងទេ?» គាត់សួរខ្ញុំដោយកែវភ្នែកមូលក្រឡង់ៗដូចជាមិនពេញចិត្ត។ ខ្ញុំហាក់តឹងតែងចិត្តដែរ ដែលមកប្រកែកឱ្យចៅហ្វាយឃ្មើស តែពិតជាចាំបាច់ត្រូវជម្រាបតាមត្រង់ ៖

«ជាងធម្មតាមិនអាចមកប៉ះពាល់របស់នេះទេទាន!»

គាត់និយាយកាត់គ្របពីលើខ្ញុំ៖

«មើលចុះប្រលាក់និងស្លកត្រង់ណោះឡើងធំ! ធម្មតាភ្ញៀវឡើងមកដល់ គេនាំគ្នាចាប់អារម្មណ៍តែរូបគំនូរនេះជាងគេ ចុះបើគេនាំគ្នាមកថតរូប.....?»

គាត់មិចភ្នែកសម្លឹងខ្ញុំដូចជាងឿងឆ្ងល់ថាខ្ញុំមិនចេះឬខ្ជិល។ ដូច្នេះខ្ញុំក៏មានតែចាប់ផ្ដើមពន្យល់បន្ថែម៖

«ជម្រាបប្រសាសន៍លោកជំទាវ ធម្មតាការជួសជុលចំណុចធ្លុះឬស្រអាប់នៅគំនូរស្បែកសត្វ យើងត្រូវធ្វើពីខាងក្រោយគំនូរមិនអាចធ្វើពីផ្នែកខាងមុខនេះទេ។ ដំបូងយើងត្រូវតម្រឹមខ្សែស្រឡាយពណ៌និងប្រើក្បាលជក់ដោយប្រុងប្រយ័ត្ននិងក្រាលក្រណាត់មួយស្រទាប់ទៀតនៅខាងក្រោយ ដែរដើម្បីផ្ដិតវាចេញ តែផ្នែកដែលពិបាក យើងត្រូវធ្វើវាឱ្យរាបស្មើ តែលោកជំទាវពិនិត្យចុះ នេះជាប្រភេទគំនូរស្ដោះ! គំនូរនេះជាទឹកដៃពិសេសរបស់អម្បូរជនជាតិតណ្ហាខាងជើង ពួកគេមិនមែនប្រើជក់ឡើយ! សណ្ឋានគ្រប់កន្លែងគ្រើមនិងមានបន្តក់ បើយើងចង់បានពណ៌វិញត្រូវតម្រឹមស្រទាប់ថ្នាំ ប៉ុន្តែបើតម្រឹមមែនយើងខូចទ្រង់ទ្រាយរូប!»

«និយាយបានល្អ!»

ស្នូរទះដៃប្រស់ៗមកពីក្រោយខ្នងខ្ញុំ។ តែជាមួយនឹងសំឡេងស្រទន់មួយទៅវិញទេ ដែលធ្វើឲ្យបេះដូងខ្ញុំលោតញាប់ សឹងធ្លាក់មកពីជណ្ដើរ។

នារីម្នាក់នេះទំនងជានារីដែលបានស្ថិតនៅក្នុងសុបិនខ្ញុំជាយូរណាស់មកហើយ។ ទោះបីជាមិនដែលបានជួបគ្នាសោះ ទើបតែឮសំឡេងក៏ដឹងថាជានាង។ បេះដូងខ្ញុំប្រាប់!

ខ្ញុំងាកភ្លាមទាំងមុខស្លឹកៗ ភ័យៗ។

ពិតជានាង ទាំងសាច់ឈាម! ហេតុអីក៏មនុស្សស្រីម្នាក់នេះនៅខាងក្រៅពិតជាក្មេងវ័យជាងនៅក្នុងទស្សនាវដ្ដីដែលខ្ញុំបានឃើញទៅទៀត?

នាងញញឹមស្វាគមន៍ខ្ញុំ តែក្រោយមកប៉ះភ្នែកខ្ញុំក៏នាងទម្លាក់ស្នាមញញឹមចោលសន្សឹមៗ។ នាងមិនដែលឃើញជាងគំនូរណាសង្ហាដូចខ្ញុំ ឬមួយក៏នាងបានមើលឃើញបេះដូងលាក់ស្នេហ៍ដ៏កំព្រាមួយនេះ តាមរយៈពន្លឺភ្នែកខ្ញុំ?

«បងឯងបានរៀនគំនូរពីសាលាណាមក?!»

«បាទ តិចតួចទេទាន!»

ខ្ញុំឈានចុះពីលើកៅអី កុំឲ្យគេពិបាកមួយក្នុងការនិយាយជាមួយខ្ញុំ។

«បានន័យថាគំនូរនេះជួសជុលមិនបាន?!»

បងស្រីគេសួររួចដកដង្ហើមធំ សម្លឹងផ្ទាំងគំនូរចុះឡើងមិនអស់ចិត្ត។ ខ្ញុំឮហើយក៏ប្រញាប់ងាកទៅរកគាត់ហើយឱនលំទោនដាក់ជាកិច្ចបញ្ជាក់ថាគ្មានលទ្ធភាពពិតមែន។

«មិនបាន មិនបាច់ជួសជុលទេ! របស់យ៉ាងម៉េចទុកអីចឹងទៅទើបមានតម្លៃ!»

ភស្សនាអ្នកនាងពៅនៃត្រកូលនេះក្រពាត់ដៃញញឹមសម្លឹងមកខ្ញុំ ទាំងមាត់គេនិយាយទៅកាន់បងស្រីឯណោះទេ។ នាងពិតជាយល់ដឹងពីវត្ថុបុរាណនិងសិល្បៈជាងនារីជាបងពិតមែន។

«អីចឹង ខ្ញុំសុំទៅធ្វើការនៅខាងក្រោមវិញសិនហើយ!»

ខ្ញុំលាពួកគេចេញមកប្រញាប់ប្រញាល់ចុះជណ្ដើរទាំងអារម្មណ៍មិននឹងនរ ជើងស្ទើរហោះម្ដងៗ។

សំឡេងរបស់គេ ស្នាមញញឹមរបស់គេ ការសន្ទនារាក់ទាក់ កែវភ្នែកភ្លឺថ្លាទាំងសងរបស់គេ ភាពឆ្លៀវឆ្លាតរបស់គេ ក្លិនរបស់គេ គ្រប់យ៉ាងកំពុងតែគ្របដណ្ដប់មកលើបេះដូងកំព្រារបស់ខ្ញុំ។

ពិធីជប់លៀងយប់នេះ យ៉ាងហោចណាស់ខ្ញុំនឹងបានឃើញគេ។

ខ្ញុំទន្ទឹងរង់ចាំឃើញកែវភ្នែកស្រទន់និងស្នាមញញឹមរបស់គេម្ដងទៀតទាំងអន្ទះសា។

មនុស្សស្រីដែលខ្ញុំបានធ្លាក់ជាប់ក្នុងបេះដូងជាយូរណាស់មកហើយដូចជាទេពនិទានដែលបណ្តាលឱ្យបានឱកាសជួបជំពើបមុខគ្នាភ្លាមៗ ក៏ស្រាប់តែមានអារម្មណ៍ចំពោះគ្នាខ្លាំងដល់ម្ល៉ឹង អុះច្រឡំ! មិនដឹងថាគេក៏មានអារម្មណ៍បែបនេះចំពោះខ្ញុំដែរឬអត់ទេ?

«ថ្ងៃណាមួយ ខ្ញុំឲ្យបងឯងគូររូបខ្ញុំ!»

សំឡេងនាងលាន់មកធ្វើឲ្យខ្ញុំសឹងរបូតជក់ពីដៃ។

ពេលនេះខ្ញុំកំពុងតែជួសជុលស្រទាប់គំនូរអំពីផ្កាឈូកនៅបន្ទប់ទទួលភ្ញៀវដែលស្លកពណ៌ខ្លះ។ ជារូបគំនូររបស់ខ្មែរយើង ទឹកដៃល្អប៉ុន្តែទំនងជាត្រូវបានគូឡើងមកយូរណាស់ហើយ ប៉ុន្តែត្រូវស្លកពណ៌មួយចំនួនប្រហែលជាមិនមានថ្នាំល្អកាលពីពេលនោះ។

គេមកដល់ពីពេលណា? ហើយធ្វើម៉េចដឹងថាខ្ញុំចេះគូរគំនូររូបមនុស្ស?

ខ្ញុំងាកទៅសន្សឹមៗ គេក៏លើកបង្ហាញទូរសព្ទនិងអេក្រង់បង្ហាញមកឲ្យខ្ញុំ ថែមទាំងសង្ស័យសួរខ្ញុំទៀតថា ៖

«គំនូរក្នុងទូរសព្ទទាំងនេះ គឺជាស្នាដៃរបស់បងឯងមែនទេ?!»

នាងលើកបង្ហាញមកខ្ញុំសុទ្ធតែជាគំនូររបស់បងធម៌ខ្ញុំឈ្មោះវិចិត្រ ប៉ុន្តែគាត់ស្លាប់បាត់ជាយូរមកហើយស្នាដៃរបស់គាត់មួយណាក៏ពិសេសលើសគេដែរ។ គាត់មិនត្រឹមជារៀមច្បងដែលខ្ញុំគោរពទេ ថែមទាំងជាគ្រូនិងជាវិចិត្រករដ៏មានទេពកោសល្យរបស់ខ្មែរ។

ខ្ញុំចំហមាត់ធ្មឹងទាំងមិនដឹងថា តើនាងទៅរកបានរូបទាំងអស់នេះពីណាមក ហើយបែរជាគិតថា ជារបស់ខ្ញុំ?

«ត្រូវហើយ រូបរបស់វីរ៉ាគូរទាំងអស់!»

ខ្ញុំបើកភ្នែកមូលក្រឡង់សម្លឹងទៅសុធីដែលមកធ្វើញញឹមញញែមនៅខាងក្រោយខ្នងនាង ហើយថ្លើមធំហ៊ានប្រាប់កុហកទៅនាង ធ្វើឲ្យនាងញញឹមឡើងកាន់តែស្រស់មករកខ្ញុំ។

«ខ្ញុំត្រូវការបងឯងបង្រៀនខ្ញុំគូររូបដៃ កាន់តែឆាប់បំផុតតាមដែលអាចធ្វើទៅបាន!»

ខ្ញុំរកហាមាត់បដិសេធប្រាប់ ដែរប៉ុន្តែនាងញញឹមស្រស់ពេកធ្វើឲ្យបេះដូងខ្ញុំគាំងៗ សូម្បីតែចលនាដៃជើងរបស់ខ្ញុំក៏គាំង កុំថាឡើយដល់ហាមាត់បដិសេធចំពោះនាង។

មនុស្សក្រីក្រ ជាងគំនូរអនាថាម្នាក់នេះហ្អីដែលនឹងមានសមត្ថភាពបង្រៀនអ្នកឌីសាញអស្ចារ្យយដូចគេ?

---

ពិធីជប់លៀងបានឈានចូលមកដល់។ ខ្ញុំនៅខាងក្រោយឆាកពិតជាអន្ទះសាចង់ឃើញគេណាស់ តែមិនមានឱកាសចេញទៅខាងមុខពិធីដើម្បីនឹងដឹងថាគេបង្ហាញខ្លួនឬនៅឡើយ។

នឹកស្មានថា ពេលវេលាដែលឪពុករបស់នាងចាត់ចែងរៀបចំកម្មវិធីបង្ហាញផ្ទាំងគំនូរពិសេសៗយកចិត្តយកថ្លើម គាត់ឱ្យខ្ញុំចេញទៅពិនិត្យ។

ផ្ទាំងគំនូរទាំងជួរលើឆាកពិតជាប្រមូលមកអស់ប្រាក់និងកម្លាំងមិនតិចនោះទេ។ លោកឪពុកនាងស្មានថា កាដូនេះអាចបង្កើតជាការភ្ញាក់ផ្អើលរំភើបដល់នាង ព្រោះនាងជាមនុស្សដែលស្រឡាញ់គំនូរខ្លាំង ដឹងអីនៅពេលដែលពិធីករប្រកាសឲ្យអ្នកនាងតូចឡើងលើឆាកទទួលយកអំណោយផ្ទាំងគំនូរ ខ្ញុំរេរកមើលនាងដូចគេដូចឯងដែរ ស្រាប់តែឃើញភស្សនាញញឹមពព្រាយមករកខ្ញុំ។

ក្នុងចំណោមមនុស្សពីជ្រុងម្ខាង អនាគតគូដណ្ដឹងរបស់នាងក៏សម្លឹងរកនាងដែរ ដូច្នេះហើយបានជាគេចាប់បានកែវភ្នែកភស្សនាដែលកំពុងតែមើលមកខ្ញុំ។

ពួកកូនប្រុសអ្នកមានទាំងអស់បង្វែរទិសដៅសម្លឹងមកខ្ញុំដោយហួសចិត្ត។ សភាពរបស់ខ្ញុំពិតជាគ្មានអ្វីដែលសមឲ្យទទួលបានស្នាមញញឹមរបស់ភស្សនាទាល់តែសោះ ទាំងសម្លៀកបំពាក់ របៀបតុបតែងនិងឋានៈកេរ្តិ៍ឈ្មោះរបស់ខ្ញុំដែលគ្មាននរណាស្គាល់ គឺច្បាស់ណាស់ខ្ញុំមិនមែនជាមនុស្សមកពីសង្គមជាន់ខ្ពស់ដូចពួកគេឡើយ។

ខណៈពេលនោះ នាងបានឈានឡើងទៅលើឆាកជាមួយរាងកាយស្រស់ស្អាតទន់ភ្លន់ ក្នុងរ៉ូបខ្លីត្រឹមជង្គង់ដូចជាស្រីតូចនៃវិមានទេពធីតា។

ពេលភស្សនានិយាយថ្លែងអំណរគុណចំពោះឪពុកនាងដែលតែងតែយល់អំពីបេះដូងនាង ថាស្រឡាញ់គំនូរ នាងមិនដែលភ្លេចចោលក្រសែភ្នែកក្រឡេកមកខ្ញុំទេ។

កាយវិការរបស់នាងម្ដងហើយម្ដងទៀត ពិតជាធ្វើឱ្យខ្ញុំភ្ញាក់ផ្អើលឡើងៗក្នុងបេះដូង។ ហេតុអីបានជាទឹកមុខគេនិងសម្ដីរបស់គេដូចជា មិនខ្វល់អ្វីទៅនឹងក្រុមកូនកំលោះអ្នកមាននិងម្នាក់ដែលឡូយសង្ហាខំមកបង្ហាញខ្លួនក្នុងនាមជាគូដណ្ដឹងជិតភ្ជាប់ពាក្យ? ហើយស្នាមញញឹមទាំងអស់របស់នាងឱ្យមកតែខ្ញុំម្នាក់ក្នុងរាត្រីកាលនេះមានន័យពិតប្រាកដយ៉ាងណាវិញ?

បេះដូងរបស់ខ្ញុំលោតច្រឡំបល់ចុះឡើង!

នាងស្រឡាញ់គំនូរពេកបានជាចូលចិត្តខ្ញុំ? តើខ្ញុំគួរឆ្លើយតបជាមួយនឹងភាពស្និទ្ធស្នាលរបស់នាងកម្រិតណាទៅ?

សម្បជញ្ញៈរបស់ខ្ញុំបានប្រាប់ខ្ញុំថា បើខ្ញុំនៅតែបន្តជាមួយនឹងរឿងដូចក្តីស្រមៃមួយនេះ បេះដូងរបស់ខ្ញុំនឹងខ្ទេចខ្ទាំដោយរបួសធ្ងន់មួយជាមិនខាន។ នេះគឺអារម្មណ៍មួយផ្នែក ប៉ុន្តែមួយផ្នែកផ្សេងទៀតបានចូលមកប្រឆាំងគ្នាដោយប្រើបញ្ជារបស់បេះដូងខ្ញុំមកប្រាប់ខ្ញុំថា ទោះបីថ្ងៃក្រោយទៅជាអ្វីក៏ដោយខ្ញុំគួរតែសប្បាយចិត្ត ដែលពេលនេះ ថ្មើរណេះ ទេពធីតាបានបង្ហាញខ្លួនយ៉ាងសប្បុរសនៅក្នុងសុបិនរបស់ខ្ញុំ។

ខ្ញុំព្យាយាមគេចភ្នែកមិនសម្លឹងឆាកទៀតខ្លាចប៉ះភ្នែកគ្នា ប៉ុន្តែបេះដូងនេះនៅបន្តលោតខុសចង្វាក់ពេញជានិច្ច។ ពេញមួយថ្ងៃមកនេះ ខ្ញុំមិនបានហូបអ្វីទាំងអស់ព្រោះពិតជារីករាយកក់ក្តៅនិងស្នាមញញឹមរបស់គេ ហើយនិងសម្តីផ្អែមល្ហែមរបស់គេដែលនិយាយមកកាន់ខ្ញុំ។ ភ្លាមនោះសំឡេងស្រទន់របស់គេបានលាន់ឡើងមកពីលើឆាកថា៖

«ហើយនៅទីនេះយើងមានវត្តមានអ្នកគូរគំនូរដ៏អស្ចារ្យម្នាក់ទៀតរបស់កម្ពុជាគឺលោក វីរ៉ា!»

ខ្ញុំស្រឡាំងកាំងព្រោះនេះមិនមែនជាស្នាដៃខ្ញុំ កេរ្តិ៍ឈ្មោះរបស់ខ្ញុំមិនសមនឹងអ្វីដែលនាងកំពុងតែប្រកាសនេះទេ។

ភ្លាមៗដោយមិនបានត្រៀងទុក សុធីរុញខ្ញុំឡើងឆាកកណ្តាលភាពត្រូបាញ់ភ្នែកសម្លឹងមកគ្រប់ច្រកល្ហក។ អ្វីៗដូចជាកំពុងតែរុញខ្ញុំឱ្យចុះនរកដូច្នោះដែរ! ការក្លែងបន្លំជានរណាម្នាក់ ពិតជាមិនសមរម្យនោះទេនោះទេ វាមិនស្រណុកចិត្តសូម្បីតែបន្តិចណាឡើយសម្រាប់ខ្ញុំ។

ថ្វីដ្បិតថានៅក្នុងប្រទេសកម្ពុជា មិនសូវមានគេយល់អំពីគំនូរច្រើន ជាពិសេសនៅក្នុងមជ្ឈដ្ឋានអភិជនមួយនេះ គេមិនយកចិត្តទុកដាក់អ្វីអំពីជាងគំនូរឬវិចិត្រកម្មដូចនៅលោកខាងលិចនោះទេ ប៉ុន្តែការកុហកពួកគេ ជាពិសេសកុហកមនុស្សស្រីដ៏ពិសេសម្នាក់នេះពិតជាមិនមែនរឿងដែលខ្ញុំចង់ធ្វើទាល់តែសោះ។

ទីបំផុតគ្រប់គ្នាសម្លឹងមកខ្ញុំ រង់ចាំខ្ញុំឲ្យឡើងទៅលើឆាកទាំងខ្ញុំឈរធ្មឹងដូចជាជាប់ការស្មិត ប៉ុន្តែសុធីបានរុញផងច្រានផង ហើយចុងក្រោយគេចុះមកបោះដៃទទួលខ្ញុំឡើងទៅជាមួយ។

ខ្ញុំងាកបន្ទាន់ទៅរកគ្រួសារនាង ឃើញពុកនាងនិងម្ដាយនាងងាកមុខចេញមិនពេញចិត្ត ឯបងស្រីនាងហាក់ខឹងស្លេក។

នាងវិញមិនរវល់នឹងអ្វីឡើយ។

«ខ្ញុំមិនមែនជាជាងគំនូរលំដាប់ប្រទេសអីទេ!»

នេះជាពាក្យដែលខ្ញុំត្រៀមនឹងនិយាយដាក់ក្បាលមេក្រូ តែមិនមានឱកាសសោះព្រោះម្រាមដៃគេដែលអូចទាញខ្ញុំឡើងទៅពិតជាធ្វើឱ្យបេះដូងនេះទន់ជ្រាយ ឯការពិតនាងកំពុងមានមោទនភាពខ្លាំងណាស់មកលើខ្ញុំប្រសិនខ្ញុំហាពាក្យនេះចេញដូចបណ្ដាលឱ្យនាងខ្មាសគេកណ្ដាលចំណោមពិធី។

ជើងខ្ញុំឈានឡើងដល់កណ្ដាលឆាកហើយ ទើបនាងលែងដៃនិងទះដៃសើចញញឹមពិតជាអបអរសាទរជាមួយខ្ញុំយ៉ាងខ្លាំងប្រាកដមែន។

នាងបាននិយាយថា ខ្ញុំគឺជាជាងគំនូរដ៏ពិសេសនៅក្នុងប្រទេសកម្ពុជា ជាគ្រាប់ពេជ្រដែលមិនទាន់ច្នៃនិងពាក្យសរសើរជាច្រើនទៀត ខ្ញុំចាំមិនអស់ទេព្រោះកំពុងតែភាន់ភាំងនឹងហេតុការណ៍មួយដែលធ្វើឲ្យយើងពីរនាក់នៅទីនេះ ក្លាយទៅជាចំណុចសុីបនៃការតាមដានពីខ្សែចក្ខុមនុស្សគ្រប់គ្នា។

ដូចការស្មានទុក ព្រឹកឡើងភ្លាមឪពុករបស់នាងបានមកដល់សណ្ឋាគារ ហើយហៅខ្ញុំចូលទៅជួបគាត់ព្រមទាំងសង្ស៊ើញសួរខ្ញុំថា តើខ្ញុំមានទំនាក់ទំនងអ្វីនឹងភស្សនា។

ខ្ញុំក៏បានប្រាប់គាត់តាមត្រង់ថា ខ្ញុំទើបតែជួបអ្នកនាងតូចនៅថ្ងៃម្សិលមិញ គឺពេលដែលត្រូវទៅរៀបចំកម្មវិធីនៅផ្ទះ។

ឪពុករបស់នាងបានប្រាប់ខ្ញុំថា ខ្ញុំត្រូវរកមធ្យោបាយកាត់ផ្ដាច់រាល់ទំនាក់ទំនងជាមួយនាងដោយមិនអនុញ្ញាតឲ្យនិយាយរកនាង សូម្បីតែតាមទូរសព្ទឬក៏ឈែតរួមគ្នា។

ខ្ញុំយល់ច្បាស់ពីបំណងគាត់។

គាត់បញ្ជាក់ទៀតថានាងមានគូដណ្ដឹងជិតភ្ជាប់ពាក្យ រឿងនេះមិនល្អឡើយសម្រាប់នាងជាភាគីខាងស្រី។ គាត់បានប្រាប់ខ្ញុំទៀតថា ទោះណាជាគាត់មិនគិតថាខ្ញុំនិងនាងមានទំនាក់ទំនងផ្លូវចិត្តតែសូម្បីតែរាប់អានឬជួបគ្នាទៀតសឹងតែមិនគួរតែម្ដង។

សម្ដីនេះគ្មានអ្វីពិបាកយល់ទេ។ ហេតុផលគឺគាត់ជាអ្នកមាន ហើយខ្ញុំជាអ្នកក្រ ចំណែកកូនស្រីពៅរបស់គាត់ស្រាប់តែមកចូលចិត្តខ្ញុំយ៉ាងពិសេស ធ្វើឱ្យខ្ញុំក្លាយជាបន្លាមុតត្រឹមមួយយប់ សម្រាប់ជីវិតគ្រួសារគាត់។

មិននឹកស្មានថាល្ងាចដដែល គេមករកខ្ញុំដល់ផ្ទះជួលដែលខ្ញុំស្នាក់នៅ។ ខ្ញុំហួសចិត្តហើយក៏មិនដឹងធ្វើបែបណាដែរ មានតែប្រាប់នាងតាមសម្រួលថា ខ្ញុំមិនចង់ពាក់ព័ន្ធជាមួយរឿងទៀតនាងទេ។ ខ្ញុំសុំឲ្យនាងឈប់ជួបខ្ញុំទៀត។

ខ្ញុំចាកចេញពីផ្ទះជួលនោះព្រោះមិនចង់នៅតទល់តែពីនាក់ជាមួយនាង ប៉ុន្តែនាងនៅតែមកតាមរហូតទាល់តែខ្ញុំត្រូវរកកន្លែងអង្គុយជជែកបញ្ចប់ជាមួយនាង។

«តើចង់បានអីពីខ្ញុំទៀត? ខ្ញុំជិតបាត់បង់ការងារហើយឃើញអត់? ឬចង់ឱ្យខ្ញុំចេញពីភ្នំពេញទៀត?»

«ទោះបងទៅដល់ណាក៏ខ្ញុំនៅតែតាមរក!»

«ហេតុអី?!»

«បងឯងមិនទាន់បង្រៀនខ្ញុំគូរគំនូរ!»

ខ្ញុំដកដង្ហើមធំ។ ប្រសិនប្រធានបទពិតរបស់នាងមានត្រឹមប៉ុណ្ណឹង ខ្ញុំនិងគ្រួសារនាងក៏មិនសមណាគិតវែងឆ្ងាយរហូតខ្ញុំត្រូវមានខ្លួនដោយខ្លួនឯងក្នុងរបៀបនេះដែរ។ អាចថានាងពិតជាមានបំណងដោយស្មោះត្រង់ក្នុងការៀនគំនូរ....

«បើមែន ជួយត្រឡប់ទៅផ្ទះវិញប្រាប់ប៉ានិងគូដណ្ដឹងផងថា ខ្លួនគ្រាន់តែចង់រៀនគូរូប! កុំឱ្យពួកគេគិតពីរឿងផ្សេងនាំទុក្ខដល់ខ្ញុំ!»

«គូដណ្ដឹងអី? ខ្ញុំមិនត្រូវការភ្ជាប់ពាក្យជាមួយបុំនោះទេ!»

ថ្ងៃនោះគេបានប្រាប់ខ្ញុំថា គេជិតដល់ថ្ងៃភ្ជាប់ពាក្យហើយ ហើយគេពិតជាមិនព្រមទទួលការរៀបគូស្រករតាមរបៀបបង្ខំនេះទេ។ ខ្ញុំហួសចិត្តខ្លាំងឡើងៗ ចរិតរបស់នាងរកតែនិយាយអ្វីក៏មិនបានហាមិនរួចមានតែអង្គុយស្ដាប់នាងនិយាយតែម្ដង។

ស្រាប់តែនាងដាក់ចោលរឿងទាំងអស់ មកនិយាយជាមួយខ្ញុំតែអំពីប្រធានបទផ្ទាំងគំនូរ និងបន្តនិយាយអំពីគំនូរនានាដែលនាងបានឃើញក្នុងវិចិត្រសាលនៅស្រុកគេ។

«ទោះយ៉ាងណា គំនូរទាំងអស់ ខ្ញុំនៅតែគិតថា មិនល្អស្មើនឹងគំនូរបងវីរ៉ានោះទេ!»

«កុំជឿសុធីទៀត! គំនូរទាំងអស់នោះមិនមែនរបស់ខ្ញុំទេ!» នេះជាឱកាសតូចមួយរបស់ខ្ញុំដែលបានពន្យល់នាងឱ្យដកចិត្តងប់ងល់នេះចេញវិញ ពេលអ្វីៗនៅមិនទាន់ស្មុគស្មាញជាងនេះ។

នាងនៅធ្វើមុខក្រឡង់ៗសម្លឹងខ្ញុំហាក់មិនជឿសូម្បីបន្តិចណាសោះ។ ពេលឃើញខ្ញុំធ្វើមុខបញ្ជាក់លើពាក្យសម្ដីមុននេះនាងស្រាប់តែផ្ទាន់ខ្ញុំវិញភ្លាមថា៖

«ល្អខ្លាំងណាស់! ប្រាប់មកម្ចាស់នៅឯណា ឱ្យលេខគេមកក៏បាន ខ្ញុំចង់ប្រមូលទិញទាំងអស់យកមកដាក់នៅក្នុងសណ្ឋាគារ! អុះ អត់ទេ ច្រឡំ! ខ្ញុំចង់បង្កើតសាលសិល្បៈមួយប៉ុន្តែមិនទាន់ដឹងថា នឹងដាក់នៅខេត្តណាមួយនៅឡើយទេគឺខ្ញុំចង់មានវា!»

ខ្ញុំហៀបនឹងហាមាត់ប្រាប់នាងថា កុំស្ដាប់សុធីអី គំនូរនោះគឺជារបស់មនុស្សម្នាក់ដែលស្លាប់បាត់ទៅហើយមិនមែនជាស្នាដៃរបស់ខ្ញុំនោះទេ ខ្ញុំក៏គ្មានសិទ្ធិសម្រេចអ្វីទាំងអស់ ស្រាប់តែនាងបើកទូរសព្ទយកផ្ទាំងគំនូរមកបង្ហាញខ្ញុំ។ ជាមួយភាពភាន់ភាំងរបស់ខ្ញុំ នាងញញឹមទាំងទឹកមុខអៀនអន់ ភ្នែកឡើងក្រហមព្រឿងដោយការពេញចិត្តធ្វើឲ្យបេះដូងខ្ញុំសឹងតែគាំងភ្លេចអ្វីៗគ្រប់យ៉ាង។

នោះជាគំនូររូបនាងក្នុងឈុតកូនក្រមុំដែលខ្ញុំបានលាក់ទុកមនោសញ្ចេតនាអនោចអធម៌ក្នុងនោះ ដឹងអីថា សុធីបានរកឃើញ ហើយថតផ្ញើនាងទៀត។

«បើមិនមែនបងឯងជាម្ចាស់គំនូរ ចុះមួយនេះអ្នកណាគូរ?»

ខ្ញុំគ្មានពាក្យបកស្រាយទេខណៈភស្សនាសម្លឹងមកខ្ញុំដោយខ្សែភ្នែកស្រទន់។

«យើងដឹងថាឯងស្រឡាញ់គេយូរហើយ ហើយថ្ងៃណាមួយបំណងរបស់ឯងនឹងបានសម្រេច! ឯងឃើញទេ ដូចយើងប្រាប់! គេជាមនុស្សស្រីល្អម្នាក់ មិនចេះប្រកាន់វណ្ណៈអីទាំងអស់! គេមិនដូចប៉ាគេដែលជាចៅហ្វាយរបស់យើងទេ! ថ្ងៃណាមួយឯងបានជោគជ័យ ឯងត្រូវតែអរគុណយើងដែលជួយចុកជួយចែវឯង!»

សុធីឈៃតមកបែបនេះ។ គេមិនទាន់ឈប់លេងទេ តែខ្ញុំវិញ មិនមានអារម្មណ៍ល្អសូម្បីតែបន្តិចណាឡើយ។

«អូខេ ខ្ញុំបង្រៀនគូររូបតែមានលក្ខខណ្ឌពីរ ទីមួយត្រូវប៉ានាងអនុញ្ញាតហើយបញ្ជាខ្ញុំផ្ទាល់មាត់! ទីពីររៀនតែមួយល្ងាចទេណា៎ ចេះមិនចេះក្ដី សន្យាថាលែងមកជួបគ្នាទៀត!»

នាងងក់ក្បាលហាក់បីដូចជាយល់ ហើយព្រមវិលត្រឡប់ទៅវិញដោយមិនមានអាការៈតឹងតែងអ្វីទាំងអស់ផ្ទុយពីបេះដូងខ្ញុំដែលមានតែពិភាល់ថា ប្រផ្នូលមិនល្អពិតជានៅចំពោះមុខហើយ។

ស្មេកឡើងពុកនាងឱ្យជំនួយការមកប្រាប់ខ្ញុំថាឱ្យទៅបង្រៀននាងគូររូបដល់ផ្ទះ។ ខ្ញុំក៏បានធ្វើទៅតាមបង្គាប់នោះមែន។ កន្លែងរៀនជាបន្ទប់ធំទូលាយមួយនៅក្បែរសួនផ្កាដ៏ស្រស់បំព្រងរបស់គ្រួសារនាង។ យើងបាននិយាយគ្នាជាច្រើនទាក់ទិនអំពីសិល្បៈនិងផ្ទាំងគំនូរនានាលើលោក។

នាងបានប្រាប់ខ្ញុំថា តាំងពីក្មេងនាងធ្លាប់គូររូបជាច្រើនដងតែមិនធ្លាប់គូរបានល្អទេ។

មួយល្ងាចនោះ ឱកាសនៅក្នុងការស្និទ្ធស្នាលជាមួយនាង ពិតជាធ្វើឲ្យបេះដូងរបស់ខ្ញុំកក់ក្តៅជាខ្លាំង។ ដ្បិតតែបង្កប់ជាមួយនូវការបារម្ភជាច្រើនក្តី ក៏មនោសញ្ចេតនារវាងខ្ញុំនិងនាងហាក់កាន់តែបង្ហាញច្បាស់ឡើងៗ អាចថាប្រហែលជាមកតែពីនាងគឺជាកូនស្រីអ្នកមាន ដែលមិនធ្លាប់រកបានអ្នកណាម្នាក់មានចំណូលចិត្តត្រូវគ្នា ឬមួយក៏យើងមាននិស្ស័យកម្មនឹងគ្នា ស្រាប់តែមានអារម្មណ៍ថា មានចិត្តទៅលើគ្នាទៅវិញទៅមកធូន់ទៅៗ។

រហូតដល់ម៉ោងប្រមាណជា៦ល្ងាចនាងនៅតែមិនឈប់សួរសំនួរ បានជាខ្ញុំចាំបាច់ត្រូវកាត់ផ្តាច់នាងដោយនិយាយឡើងថា៖

«អ្នកនាងពៅសន្យាពីម្សិលរួចហើយថា ការរៀនគំនូរជាមួយខ្ញុំនឹងមិនឱ្យលើសពីមួយល្ងាចទេ!»

ស្រាប់តែនាងបែរមកនិយាយនឹងខ្ញុំខ្សឹបៗថា៖

«យប់នេះយើងទៅញ៉ាំបាយជាមួយគ្នាទៅ ជាការងសងគុណនិងចែកសញ្ញាបត្រ!»

តាមពិតខ្ញុំមិនហ៊ានទេ បើសិនជាឲ្យខ្ញុំជាអ្នកបបួលនាង ប៉ុន្តែនាងហាក់ដូចជាបង្ហាញការត្រៀមខ្លួនជាស្រេចនៅក្នុងការ ផ្លាស់ប្តូរមនោសញ្ចេតនាជាមួយខ្ញុំ។

«ខ្ញុំរវល់!»

មាត់ខ្ញុំពិតជាបដិសេធផ្ទុយនឹងចិត្ត។

«អាចហៅប៉ាឬគូដណ្តឹងជូនទៅបាន!» ខ្ញុំបន្ថែមពេលភស្សនាធ្វើមុខស្រពោន។

ស្រាប់តែនាងតបតមកវិញ៖

«ខ្ញុំមិនចង់រៀបការទេ! ខ្ញុំនៅក្មេងយ៉ាងនេះ ហេតុអីបានជាបងឯងគូររូបនាងនាគឲ្យខ្ញុំដោយគ្មានការអនុញ្ញាត បងឯងត្រូវពិន័យហើយ!»

«ព្រោះខ្ញុំ...ឮថាអ្នកនាងជិតរៀបការ!»

«គួដណ្ដឹងម្នាក់នោះ ខ្ញុំមិនស្រឡាញ់ទេ! ដូច្នេះគ្មានការភ្ជាប់ពាក្យអ្វីកើតឡើងទាំងអស់! បងឯងជឿខ្ញុំទៅ !»

«ហេតុអីទៅ? អ្នកទាំងពីរសក្តិសមគ្នាខ្លាំងណាស់!»

«ខ្ញុំរកបានមនុស្សដែលខ្ញុំស្រឡាញ់ហើយ! ជាតិនេះខ្ញុំស្រឡាញ់តែគេទេ!!»

ខ្ញុំភាំងៗពេលគេនិយាយត្រង់ណោះហើយចោលភ្នែកស្រទន់មើលមកខ្ញុំ។ គេបន្ថែមពាក្យខ្សាវៗមកក្នុងប្រស្រីភ្នែកខ្ញុំ៖

«គេមានចំណូលចិត្តដូចខ្ញុំណាស់ លើកណាក៏ខ្ញុំមានអារម្មណ៍សប្បាយចិត្តខ្លាំងរាល់ពេលនៅក្បែរគេ!»

ទីបំផុតទៅគឺរាល់ពាក្យសម្ដីដែលគេកំពុងនិយាយឡើង ភាគច្រើនធ្វើឲ្យបេះដូងខ្ញុំទន់ដូចសំឡីលែងចង់គ្រប់គ្រងអ្វីៗបាន។

បើខ្ញុំពន្យារនៅតែបន្តិចទៀត ខ្ញុំអាចនឹងលង់លែងគិតដល់អ្វីៗទាំងអស់ដែលជាឧបសគ្គនៅចំពោះមុខ។ ដៃខ្ញុំស្រវេស្រវារៀបចំសម្ភារៈ ហើយតាំងចិត្តថាមិនស្ដាប់នាងទៀតដាច់ខាត។

«យប់នោះ នៅកន្លែងស្ងាត់ៗតែពីរនាក់!! អ្វីៗដែលយុវវ័យនៅប្រទេសលោកខាងលិចធ្វើ ហើយដែលខ្ញុំធ្លាប់គិតថាមិនសមរម្យ បានកើតឡើងរវាងខ្ញុំហើយនិងគេ!»

នាងនិយាយតិចៗ.....

និយាយមកកាន់ខ្ញុំ? ដៃខ្ញុំទ្រឹង! អ្វីមួយមិនប្រក្រតីរំញោចឡើងក្នុងចិត្តខ្ញុំ....

សន្សឹមៗខ្ញុំងៀងភ្នែកសម្លឹងមកភស្សនា...កូនពៅអភិជនកំពុងតែញញឹមតែទឹកភ្នែកនាងស្រក់រហាច.....

«ខ្ញុំមិនខ្វល់ឡើយ ថានឹងមានអ្វីកើតឡើងទេ! យើងស្រឡាញ់គ្នាណាស់! ចុងក្រោយ គេបានដាស់ឱ្យខ្ញុំអង្គុយឡើង ហើយគេផ្ទាល់ជាអ្នកគូររូបឲ្យខ្ញុំប្រកបដោយសុភមង្គល! គូរពេញមួយយប់ទល់ភ្លឺ»

ខ្ញុំឡេឡឺហើយ....នាងកំពុងនិយាយអំពីអ្នកណា? ខ្ញុំគិតមិនយល់ទេ ម៉េចនាងធម្មតាៗប្រែប្រួលទៅដូចជាមានខ្មោចចូល?

«លោកគ្រូវីរ៉ាអញ្ជើញទៅវិញបាន!»

សំឡេងបងស្រីគេលាន់មកពីមាត់ទ្វារទំនងជាអ្នកនាងធំគ្រួសារនេះតាមលបសម្លឹងពួកយើងជាយូរមកហើយ។ ខ្ញុំថយក្រោយមួយជំហានពេលអ្នកនាងធំបង្ហាញខ្លួនជាមួយអង្គរក្សមាឌធំពីរនាក់។

«បើអ៊ីចឹងដដែលហេតុអីយើងស្គាល់គ្នា?»

គេនិយាយឡើងទៀតក្នុងសូរសព្ទអាក់រអួលក្ហួរគលក។

ខ្ញុំតក់ស្លុត....សភាពរបស់គេនិងបងស្រីគេដែលសំដៅចូលមក បង្ហាញថាអ្នកនាងពៅដែលខ្ញុំលបស្នេហ៍មិនមានសតិធម្មតាទេ។ នាងឈឺអី?

នាងនិយាយពីរឿងអី?

ម្សិលមិញនិងថ្ងៃនេះ ពេលរៀនគូរគំនូរនាងមើលទៅប្រក្រតីសោះ?

«តោះ! ទៅសម្រាក បងនិយាយរឿងគំនូរឱ្យស្ដាប់!»

បងស្រីគេដើរចូលមកនិយាយជាមួយគេ ខណៈអង្គរក្សស៊ីញ៉ូដៃឱ្យខ្ញុំចាកចេញ។ ដោយភាំងៗ ខ្ញុំទាញខ្លួនឯងឆ្ពោះទៅរកមាត់ទ្វារ ស្រាប់តែសំឡេងភស្សនាលាន់មកសន្ទប់វិញ្ញាណខ្ញុំ....

«លែងគេ! កុំសម្លាប់គេ....!»

វត្ថុវិចិត្រកម្មទាំងអស់ ជ្រុះរបូតពីហត្ថាគ្មានកម្លាំងកំហែងរបស់ខ្ញុំ។

ម្ដងណេះសំឡេងនាងមុតស្រួចជាងគ្រាប់បែក ខណៈបងស្រីរបស់នាងទើបតែលោដៃទៅមិនទាន់ប៉ះដល់សាច់នាងផង។

ប្រតិកម្មនាងរឹតតែធ្ងន់ធ្ងរហើយ។ ខ្ញុំមិនគួរនៅទីនេះយូរទេ.....

ខ្ញុំឱនកាយធ្វើសញ្ញាលាកូនស្រីច្បងរបស់ថៅហ្វាយខ្ញុំហើយសសៀរចាកចេញ ស្របពេលរបស់មួយហើរមកប៉ះក្បាលខ្ញុំពីចំហៀងគឹប...

....របស់អីមិនដឹងទេ....វាតូចល្មមតែរឹង ហើយឈឺស្ពឹកចំគោលដៅដែលវាតម្រង់....។

ក្នុងមួយវិនាទីនៃអារម្មណ៍តក្កមា ខ្ញុំនៅតែការពារថាមិនមែននាងទេ អ្នកដែលគប់ខ្ញុំ! ព្រោះវាចូលមកពីទិសដៅផ្សេង.....!

មុនពេលដួលផ្ងោលទៅលើដី ខ្ញុំមើលឃើញចុងក្រោយនូវរូបរាងមនុស្សម្នាក់លឹបលក្បែរបង្អួចនៅក្នុងសួនច្បារខាងក្រៅ។ មើលត្រឹមតែមួយប៉ប្រិចភ្នែក ក៏ខ្ញុំស្រដៀងសុធីដែរ។

តើសុធីមកដល់ទីនេះពីថ្មើរណា? ហើយតើគេមានបំណងអ្វី? គេចង់គប់អ្នកណាទៅបានជាមិនត្រូវមកត្រូវសៀតផ្កាខ្ញុំ? ប៉ុន្តែខ្ញុំគ្មានគេពេលគិតលើសពីនេះទៀតទេ ខ្ញុំដួលត្មោលរមៀលទន់អវយវៈទាំងអស់ ប៉ុន្តែអារម្មណ៍របស់ខ្ញុំនៅដឹង។

ខ្ញុំឃើញនាងកញ្ច្រោលមករកខ្ញុំដោយស្ទុះឱបខ្ញុំទាំងទឹកភ្នែកស្រោក់។

ខ្ញុំនិយាយមិនកើតនោះទេ។ ដុំគ្រួសឬថ្មមួយនោះពិតជាបំបុកចំកន្លែងសំខាន់ណាមួយនៃក្បាលខ្ញុំ.....

«ប្រាប់ថាកុំធ្វើអីគេ! កុំសម្លាប់គេ! អ្នកទាំងអស់គ្នាសម្លាប់គេម្តងហើយ ហេតុអីបានមកសម្លាប់គេម្តងទៀត?!»

ខ្ញុំមិនយល់នូវសាច់រឿងទាំងអស់ដែលភស្សនាកំពុងតែនិយាយនោះទេ។

ខ្ញុំឃើញចុងក្រោយនូវតំណក់ទឹកភ្នែកនិងសភាពឆ្កួតលីលាវង្វេងវង្វាន់នៅលើផ្ទៃមុខរបស់នាងព្រមទាំងការស្ទុះចូលរបស់បងស្រីនាងដើម្បីទាញនាងយកចេញពីខ្ញុំ ប៉ុន្តែមិនដឹងជាភស្សនានាងមានកម្លាំងខ្លាំងដូចដំរីចុះប្រេងមកពីណា គ្រលាស់គ្រវែងគ្រវាត់ជំទាវភស្សនាដ ឱ្យខ្ទាតចេញទៅ សូម្បីតែស្រែកកម្រោលរើលើកតុ កៅអីរារាំងបោះសំដៅទៅរកក្រុមអង្គរក្សក៏នាងធ្វើបាន។

មនុស្សក្នុងផ្ទះរត់ចូលមកច្រើនឡើងៗ ខ្ញុំទន់ត្របកភ្នែកសន្លប់ឈឹងលែងដឹងអ្វីទាំងអស់.....

ខ្ញុំបើកភ្នែកឡើងវិញ ឃើញខ្លួនឯងនៅក្នុងបន្ទប់សម្រាកព្យាបាលមួយ គ្មានឃើញគ្រួសារមហាសេដ្ឋីឬសូម្បីសុធីបងចាន់ថុលនោះទេ។ អ្នកដែលនៅក្បែរខ្ញុំគឺម្តាយខ្ញុំនិងម្តាយមីងរបស់ខ្ញុំ។ រាល់ពេលដែលខ្ញុំមានបញ្ហាមានតែម្តាយខ្ញុំនិងម្តាយមីងរបស់ខ្ញុំ ជាមនុស្សតែពីរនាក់គត់ដែលបង្ហាញខ្លួនព្រោះខ្ញុំជាកូនទោលនិងគ្មានពុកដូចគេ។

«ខ្ញុំកើតអី?!»

ខ្ញុំសួរទាំងល្វឹងមាត់ ភ្នែករេចុះឡើងទៅប៉ះនឹងប្លោកសេរ៉ូមលើក្បាលក្បែររឹងស្ងួតអស់ទឹកទៅហើយ។

«កូនលែងអីហើយ! យើងចេញទៅស្រុកវិញបាន! ចាំបងជីដូនមួយឯងមកឥឡូវហើយ គេទៅបង់លុយ!»

នេះគឺជាអ្វីដែលម្តាយខ្ញុំប្រាប់ខ្ញុំ ។

ខ្ញុំខំរកនឹក រំឭកឡើងវិញនូវព្រឹត្តិការណ៍ទាំងអស់ដែលបានកើតឡើងមុនពេលដួល តើវាគ្រាន់តែជាសុបិននៃភាពឆ្កួតលីលារបស់ខ្ញុំព្រោះតែលួចស្រឡាញ់កូនគេខ្លាំងពេក ឬមួយក៏វាពិតជាបានកើតឡើងចំពោះខ្ញុំមែន?

ល្ងាចដដែលនោះត្រលប់ដល់ផ្ទះខ្ញុំបានលបស្ដាប់ឮម្ដាយខ្ញុំនិយាយនឹងអ្នកជិតខាងថា ខ្ញុំត្រូវគេគប់មួយដុំគ្រួស ជាមនុស្សម្នាក់ដែលបានជួលបន្ទប់នៅរួមគ្នាជាមួយខ្ញុំ។

សុធី?

ហេតុអីបានជាវាគប់ខ្ញុំ?

ពេលនេះសុធីនៅឯណា?

ពេលដែលខ្ញុំទៅសួរម្ដាយនូវសំណួរនេះគាត់មិនមាត់ បានត្រឹមសម្លឹងមកខ្ញុំភ្លឹះមិនមានចម្លើយ។ គាត់ក៏មិនដឹងដែរថាហេតុអីបានជាអ្នកជួលបន្ទប់នៅជាមួយខ្ញុំគប់ខ្ញុំ។

យើងបៀមទុកនូវចម្ងល់នេះហើយទាក់ទងសុធីមិនបានទេ។ រហូតដល់បួនថ្ងៃក្រោយមក ទើបបានបងចាន់ថុលប្រធានផ្ទាល់របស់ខ្ញុំបានឡើងមកលេងខ្ញុំនៅផ្ទះ។ ពេលនោះហើយគាត់បានប្រាប់ខ្ញុំថា ថៅកែមិនបានបណ្ដេញខ្ញុំចេញទេអាចទៅធ្វើការវិញធម្មតា ណាមួយគេនឹងទូទាត់ថ្លៃព្យាបាលជំនួសយើងទៀត។

អំពីដំណើររឿងទាំងអស់ដែលបានកើតឡើងចំពោះគ្រួសារមហាសេដ្ឋីមួយនោះ តើរឿងពិតវាយ៉ាងណាហើយពាក់ព័ន្ធអ្វីជាមួយសុធីនិងរបួសរបស់ខ្ញុំទើបជាអ្វីដែលខ្ញុំទទូចចង់ដឹង។ ដោយមិនអាចលាក់លៀមបានគាត់ប្រាប់ខ្ញុំតាមត្រង់៖

«អ្នកនាងភស្សនាតាមពិតមិនបានទៅបរទេសនិងមិនបានទៅសិក្សាបន្តអ្វីដូចដែលគ្រប់គ្នាក្នុងសណ្ឋាគារយើងបានដឹងមកនោះឡើយ! ឮថាគាត់មានជំងឺធ្ងន់ធ្ងរណាស់ចាប់តាំងពីសង្សារដំបូងរបស់គាត់ដែលចួបគ្នានៅស្រុកក្រៅត្រូវស្លាប់!»

«ជំងឺអ្វី?!» ខ្ញុំសង្ស័យសួរទាំងពិភាល់ក្នុងអារម្មណ៍។

«PTSD»

«ស្អីទៅ PTSD?»

បងចាន់ថុលបានឱ្យខ្ញុំដឹងថា នោះជារោគសញ្ញាស្រ្តេសធម្មតាៗនៅក្រោយការប៉ះទង្គិចផ្លូវចិត្ត ថប់បារម្ភបន្ទាប់ពីការស្លាប់ទាន់ហន់នៃមនុស្សជិតស្និទ្ធ។ ដំបូងៗគ្រួសារនេះយល់ថានាងមាន PTSD ជាធម្មតា ដោយមិនគិតពីបញ្ហា ប៉ះទង្គិចផ្លូវចិត្តធំឡើងៗដូចជំងឺមហារីកនោះទេ។

ធម្មតាអារម្មណ៍សោកសៅ រមែងអាចត្រូវរម្ងាប់បានទៅតាមពេលវេលា។ តែចំពោះការស្លាប់ដ៏តក់ស្លុតនិងការបំបែកពីគ្នាយ៉ាងទាន់ហន់ដោយឃោរឃៅមួយ មិនមែនជារឿងធម្មតាសម្រាប់មនុស្សពីរនាក់ដែលទើបតែបានស្រឡាញ់គ្នាយ៉ាងជ្រាលជ្រៅនោះឡើយ។

នារីនេះបានបណ្តោយខ្លួនទាំងស្រុងទៅក្រោមការគ្រប់គ្រងដោយវិប្បដិសារៈនៃការបាត់បង់យ៉ាងសោកនាដកម្ម។ ឯសង្សាររបស់នាងម្នាក់នោះគ្មានអ្នកណា ក្រៅពីជាងគំនូរដ៏ល្បីឈ្មោះ«វិចិត្រ»ដែលជាគ្រូដើមរបស់ខ្ញុំនោះទេ។

ខ្ញុំបែកពីគាត់ច្រើនឆ្នាំដែរហើយ មិននឹកស្មានថាមួយរយៈនោះគាត់បានកសាងស្នេហាអាថ៌កំបាំងនៅស្រុកគេនៅក្នុងឱកាសដែលគាត់ទៅពិព័រណ៍រូបថតនៅបរទេសហើយបានជួបនាង។

រឿងរ៉ាវរបស់ភស្សនាត្រូវបានគេបកស្រាយនិងបោះផ្សាយជាសាធារណៈលាតត្រដាងពេញបណ្តាញសង្គមបំផ្លាញគ្រប់យ៉ាងដែលគ្រួសារមហាសេដ្ឋីប្រឹងលាក់លៀម។

សូម្បីរូបគំនូរចុងក្រោយដែលជាងគំនូរខ្មែរដ៏ល្បីឈ្មោះវិចិត្របានគូរឲ្យនាង និងធ្លាប់ត្រូវបានឪពុករបស់នាងប្រមូលទិញយកដុតចោលខ្ទេចខ្ទីអស់ប៉ុន្តែសំដៅ Digital ដើមនៅតែត្រូវបានចែកចាយចេញក្នុងពេលនេះ។

ពេលនោះហើយយើងដឹងថា សុធីគឺជាប្អូនប្រុសបង្កើតរបស់វិចិត្រ។

គេមិនដែលនិយាយប្រាប់ខ្ញុំទេ ដោយសារតែសុធីមានបំណងចង់សងសឹកចំពោះគ្រួសារមួយនេះ។

គេចង់លាតត្រដាងពីរឿងកូនស្រីគ្រួសារមួយនេះមានជំងឺសរសៃប្រសាទបន្ទាប់ពីបងប្រុសគេស្លាប់។ ជំហានដំបូងសុធីបានមករកខ្ញុំនិងបបួលឲ្យចូលធ្វើការនៅសណ្ឋាគារជាមួយគេ ថែមទាំងអនុញ្ញាតឱ្យខ្ញុំនៅផ្ទះជួលជាមួយគេ។ សូម្បីតែខ្ញុំស្រឡាញ់នាង ក៏ប្រហែលជាផ្នែកមួយនៃសេណារីយ៉ូរបស់សុធីពីព្រោះគេតែងតែនិយាយអំពីនាង បង្ហាញនូវទស្សនាវដ្តីរបស់នាង បង្ហាញនូវរូបថតល្អៗនិយាយសសើរទឹកចិត្តសប្បុរសរបស់នាងប្រាប់មកខ្ញុំ។ សុធីបានកសាងដំណើររឿងនេះឡើងដើម្បីជាការសងសឹកប៉ានាង ឯខ្ញុំគឺជាគ្រាន់តែជាតួអង្គមួយដែលគេត្រូវលះបង់នៅក្នុងសេណារីយ៉ូមួយនេះ។

រាល់ពេលខ្ញុំលួចគូររូបនាង ខ្ញុំស្មានថាអ្វីៗទាំងអស់រំលងពីភ្នែកគេបាន ប៉ុន្តែគេបានយកផ្ញើទៅនាង គេថែមទាំងបំភាន់ភស្សនាថា ខ្ញុំគឺជាវិចិត្រ។ អ្វីៗទាំងអស់គឺជាល្បិចកលរបស់គេនៅក្នុងការធ្វើឲ្យជំងឺនាងរកាន់តែធ្ងន់ឡើងៗ។

ក្រោយបំផុតនេះសុធីបានស៊ើបដឹងរឿងថា នាងជិតបានចេញពីមន្ទីរព្យាបាលសម្រាប់មនុស្សដែលមានបញ្ហាសរសៃប្រសាទ។ នៅថ្ងៃនោះឪពុកនាងបានរៀបចំកម្មវិធីទទួលនាងត្រឡប់មកផ្ទះវិញ ដោយទិញមកជាជំនូននូវផ្ទាំងគំនូរមហាសាលថ្លៃៗជាច្រើនមកផ្គាប់ចិត្តនាង ប៉ុន្តែសុធីបានផ្ញើរូបដែលខ្ញុំគូរឲ្យនាងវង្វេងថាជាស្នាដៃរបស់វិចិត្រ ហើយថែមផ្ញើរូបភាពជាច្រើនទៀតទាក់ទងជាមួយនឹងស្នាដៃដើមរបស់សង្សារនាង។

មនុស្សដែលបម្រុងតែនឹងជាសះស្បើយ បែរជាធ្ងន់ធ្ងរលើសដើមនៅពេលដែលរឿងចាស់ត្រូវបានគេរំឭកមកវិញដោយប្រើមនុស្សពិតៗនិងរូបគំនូរ។

រាល់ពេលនាងនិយាយជាមួយខ្ញុំ ភាគរយតិចតួចនាងគិតថាជាខ្ញុំ ភាគរយច្រើននាងស្រមៃថាជាសង្សារនាង។

នៅពេលដែលជំងឺរបស់នាងកាន់តែធ្ងន់ឡើងៗ ការចងចាំចាស់ៗនៃដំបៅក្នុងបេះដូងរបស់នាងកាន់តែកក្រើករំពើកមកវិញ។ គេចាប់ផ្ដើមគប់ខ្ញុំឲ្យដួលដែលធ្វើឲ្យនាងយល់ថា គ្រួសារនាងបានសម្លាប់សង្សារនាងជាលើកទីពីរ។

«ខ្ញុំសូមអង្វរបង! ខ្ញុំចង់ដឹងរឿងបងវិចិត្រ! តើគាត់ត្រូវគេសម្លាប់មែនទេ?!»

«មានពាក្យចចាមអារ៉ាមដូច្នេះ! តែមែនឬអត់មិនអាចកំណត់បានទេ!» បងចាន់ថុលឆ្លើយបែបនេះហើយក៏លែងនិយាយអ្វីទៀត។

មិនយូរប៉ុន្មានកំណត់ហេតុរបស់នាងមួយ ត្រូវបានគេចែកចាយ។ អ្នកចែកចាយនោះ គ្មានអ្នកណាក្រៅពីសុធីទេ។ ខ្ញុំអានរឿងរ៉ាវអតីតកាលរបស់នាងដោយចប់បារម្ភ.....

ឆ្នាំ២០១៤ បន្ទាប់ពីត្រូវបានក្រុមដៃជើងរបស់ប៉ានាងវាយដំដល់ហាងដែលគេជួលលក់គំនូរដោយសារបញ្ហាវណ្ណៈ មហាសេដ្ឋីកំណាចមិនព្រមឲ្យវិចិត្របានវិលត្រឡប់មកឈរជើងនៅភ្នំពេញទៀតនោះទេ ដូច្នេះវិចិត្រករដែលលុះក្រោមការគំរាមកំហែងបានយល់ព្រមចាកចេញដើម្បីសុវត្ថិភាព។ ដឹងអីនៅខាងក្រៅផ្ទះគេ នាងបានបង្ហាញខ្លួនហើយថាចង់ចេញទៅជាមួយគ្នា។ ពេលនោះហើយដែលវិចិត្រត្រូវគ្រោះថ្នាក់ចរាចរណ៍នៅក្នុងការប្រទាញប្រទង់មួយជាមួយនាងរួចស្លាប់នៅក្នុងថ្លុកឈាមនៅនឹងមុខនាង។

ចាប់ពីពេលនោះមកគ្មាននរណាបានដំណឹងពីអ្នកនាងពៅភស្សនាទៀតនោះទេ។ គ្រប់គ្នានិយាយថានាងទៅបន្តការសិក្សាបំភ្លេចរឿងចាស់ៗនៅភ្នំពេញ ប៉ុន្តែប្រភពខ្លះបាននិយាយថា នាងនៅព្យាបាលជំងឺសរសៃប្រសាទដ៏ធ្ងន់ធ្ងរជាមួយនឹងការបង្ខាំងនៅក្នុងផ្ទះ បន្ទាប់មកក៏បញ្ជូនទៅកាន់មន្ទីរពេទ្យ។

ថ្ងៃជប់លៀងប៉ុន្មានថ្ងៃមុននេះគឺជាថ្ងៃដែលនាងស្រាកស្រាន្តត្រូវបានគ្រូពេទ្យអនុញ្ញាតឲ្យត្រឡប់មកផ្ទះវិញតែត្រូវបានសុធីរៀបចំគម្រោងការបំផ្លាញដោយមានខ្ញុំជាតួអង្គ។

«ចុះគេពេលនេះយ៉ាងម៉េចទៅហើយ?» ពាក្យនេះខ្ញុំចង់សួរណាស់ ខ្ញុំនៅតែចង់ដឹងពីសុខទុក្ខរបស់នាង តែមិនដឹងត្រូវសួរអ្នកណា? វាក្លាយជាសំណួរដ៏ធំមួយបង្កប់នៅក្នុងចិត្តខ្ញុំ។

ខ្ញុំក៏មិនចង់ដឹងដែរថា សុធីឥឡូវនៅគេចខ្លួនដល់ណាឬមួយក៏ត្រូវគេចាប់បានប៉ុន្តែ ខ្ញុំពិតជាអាណោចអាធ័មចំពោះរឿងរ៉ាវរបស់កូនស្រីពៅចៅហ្វាយខ្ញុំពេកណាស់។

«បំភ្លេចចោលរឿងទាំងអស់ទៅកូន! រឿងពាក់ព័ន្ធជាមួយគ្រួសារមួយនោះ គឺជារឿងដែលនាំមកនូវភ័ព្វអាក្រក់សម្រាប់កូនតែប៉ុណ្ណឹង! ឥឡូវនេះយើងមកនៅឆ្ងាយពីភ្នំពេញហើយ ប្រកបរបរនៅខេត្តរបស់យើងក៏បាន បានប៉ុន្មានយកប៉ុណ្ណឹងទៅ! ស្រឡាញ់គេមានជាងយើងពេកមិនដែលបានលទ្ធផលល្អទេ!»

នេះជាអ្វីដែលម្ដាយខ្ញុំអង្វរខ្ញុំ ម្ល៉ោះហើយខ្ញុំក៏ធ្វើតាមគាត់ ដោយប្រាប់ខ្លួនឯងថាគ្រប់យ៉ាងដែលបានកើតឡើងរវាងនាងនិងខ្ញុំគឺជាការភាន់ច្រឡំនៃមនុស្សវិកលម្នាក់ ដែលមិនដឹងអ្វីទាំងអស់ព្រោះឥទ្ធិពលនៃវិបត្តិអតីតកាលឲ្យនាងវង្វេងវង្វាន់ ច្រឡំនឹកស្មានថា ខ្ញុំនេះជាសង្សារចាស់របស់នាង។

ប្រមាណជាប្រាំមួយខែកន្លងផុតទៅខ្ញុំបានដំណឹងថា នាងនៅរស់ក្រោមការគ្រប់គ្រងរបស់គ្រួសារយ៉ាងតឹងរឹង ចំណែកឯគូដណ្ដឹងដែលល្បីថាប្រុងរៀបការជាមួយនាងក៏បានដកពាក្យរួចទៅហើយ ដោយសាររឿងរបស់នាងត្រូវបានបង្ហើបត្រដាងសុះសាយដោយសុធីដើម្បីសងសឹកឲ្យបងប្រុសគេ។

សុធីក៏បាត់ស្រមោលដដែលព្រោះប៉ូលិសតាមចាប់ទៅតាមពាក្យបណ្ដឹងរបស់ក្រុមគ្រួសារនាង។

មនុស្សជាច្រើនបានរងគ្រោះដោយសារតែសេចក្ដីស្នេហាពីអតីតកាលមួយដែលបង្កប់នូវការឈឺចាប់ដល់មនុស្សនៅរស់ពីរនាក់ ហើយមនុស្សម្នាក់បានបាត់បង់ជីវិត។ ចំណែកខ្ញុំជាស្អីដែរ ដែលចង់ក្លាយជាផ្នែកមួយ ក្នុងចំណោមអ្នករងគ្រោះបន្ថែមជាមួយរឿងនេះ?

«វីរ៉ាមានរបស់គេផ្ញើមកកូន! ជាគំនូរហើយមើលទៅ?!»

ម្ដាយខ្ញុំហុចប្រអប់ធំមួយមកឲ្យខ្ញុំ។ តើអ្នកណាគួរផ្ញើរគំនូរផ្ញើមកអ្នកគូរគំនូរដូចខ្ញុំទៅ?

ខ្ញុំហែកបើកមើលហើយភ្ញាក់សឹងរបូតពីដៃ។ នោះគឺជារូបរាងរបស់គេ អ្នកនាងពៅភស្សនាក្នុងឈុតគេងរាត្រីស៊ិចស៊ី។ គ្រប់យ៉ាងនៅទីនេះ ពិតជាស្អាតដូចជារូបភាពផ្ដិតពីកាមេរ៉ាពិតៗ សូម្បីបរិយាកាសនៅក្រៅបង្អួច ពន្លឺព្រះចន្ទ ស្រមោលវាំងននបោកតាមកម្លាំងវាយោ ការលាយពណ៌ខៀវស្រទន់នាំមកនូវអារម្មណ៍មួយនារាត្រីកាលដ៏ពិសិដ្ឋ ពិតជាកម្រងទឹកដៃនៃកំពូលវិចិត្រករមិនអាចបន្លំច្រឡំគ្នាជាមួយស្នាដៃក្លែងក្លាយបានឡើយ។

«បងវិចិត្រ?!»

ក្នុងនោះ....នារីម្នាក់នោះ...អង្គុយញញឹមប៉ប្រិមឲ្យជាងគូររូបនាង។

បេះដូងខ្ញុំទទួលដឹងថា នេះជាគំនូរចុងក្រោយ....សល់ពីស្នេហាដ៏ជ្រាលជ្រៅរបស់ពួកគេនាយប់មួយនោះ។ សំឡេងនាងលាន់មកក្នុងសោតាខ្ញុំជាថ្មី «យប់នោះ នៅកន្លែងស្ងាត់ៗតែពីរនាក់! អ្វីៗដែលយុវវ័យនៅប្រទេសលោកខាងលិចធ្វើ ហើយដែលខ្ញុំធ្លាប់គិតថាមិនសមរម្យ បានកើតឡើងរវាងខ្ញុំហើយនិងគេ!» «ខ្ញុំមិនខ្វល់ឡើយ ថានឹងមានអ្វីកើតឡើងទេ! យើងស្រឡាញ់គ្នាណាស់! ចុងក្រោយគេបានដាស់ឱ្យខ្ញុំអង្គុយឡើង គេគូររូបខ្ញុំពេញមួយយប់ទល់ភ្លឺ»

រាត្រីកាលដែលពួកគេសុខសាន្តជាមួយគ្នា ហាក់លេចឡើងស្ថិតនៅចំពោះមុខខ្ញុំ តាមរយៈផ្ទាំងគំនូរមួយនេះ។ ខ្ញុំដៀងភ្នែកមករឹមខាងក្រោម.....ជាងគំនូរដូចយើងតែងដឹងថា ប្រសិនបើអ្នកគូរចង់បន្សល់ទុកពាក្យពេចន៍អ្វីមួយ គេនឹងសរសេរនៅគែមក្រោមខាងឆ្វេងបង្អស់...មែន! មានអក្សរតូចៗមួយជួរនៅទីនោះ...ខ្ញុំផ្ទង់អានវា....«លុះលង់តឡូវ នៅតែស្រឡាញ់» វិចិត្រ។

**ចប់**